# ក្តារផ្គុំ/រៀបអក្សរក_ខ

ការអភិវឌ្ឍន៍ភាសាគឺត្រូវចាប់ផ្តើមតាំងពីពេលចាប់កំណើតក្នុងផ្ទៃម្តាយមកម្លេះ។ ទារកឮសូរសំលេងរបស់ម្តាយ និងអ្នកនៅជុំវិញខ្លួនម្តាយតាំងពីនៅក្នុងផ្ទៃ។ គេនិយាយថា នៅពេលពរពោះបាន៥ខែ មុខងារនៃសរីរាង្គនីមួយៗរបស់រាងកាយទារកចាប់ផ្តើមបង្កើត ពេលបាន៦ខែ វាចាប់ផ្តើមវិវឌ្ឍន៍ធំឡើងៗ។ ជាពិសេសក្រោយពេលកើតបាន៤-៥ខែ សោតវិញ្ញាណរបស់ទារក អភិវឌ្ឍន៍បានពេញលេញ។ ហេតុដូច្នេះហើយនៅក្នុងចំណោមការស្តាប់ ការនិយាយ ការអាន និង ការសរសេរ ទារកអភិវឌ្ឍន៍ ការស្តាប់បានមុនគេ។ ប្រសិនបើទារកអភិវឌ្ឍន៍តាមធម្មតា ទារកអាចអភិវឌ្ឍន៍ពីការស្តាប់មកការនិយាយបាន។ ការអភិវឌ្ឍន៍នេះមានគំលាតទៅតាមទារកដែរក៏ប៉ុន្តែទារកមានអាយុចាប់ពី៣ខែឡើងទៅ វាចាប់ផ្តើមរៀននិយាយអា~អា~ អ៊ូ~អ៊ូ~ (ចាប់ផ្តើមចេះកកេកករ)។ នៅពេលនោះគឺជាពេលចាំបាច់បំផុតដែលម្តាយនិងអ្នកនៅជុំវិញខ្លួនទារកត្រូវទទួលសំដីនិងឆ្លើយ តបទៅទារកវិញ ដើម្បីអោយទារកមានការអភិវឌ្ឍន៍ផ្នែកភាសានៅពេលក្រោយ។ នៅពេលកុមារមានអាយុ២ឆ្នាំ កុមារអាច ចេះនិយាយ ហើយពេលអាយុ៣ឆ្នាំ កុមារបង្កើតបាននូវមូលដ្ឋានគ្រឹះនៃភាសានិយាយ។ ចំពោះការអាន និងការសរសេរវិញ ចំបាច់ត្រូវចាប់ផ្តើមពីបទពិសោធន៍នានានិងការរៀបចំពាក្យនិយាយបណ្តើរចងភ្ជាប់ជាមួយបរិស្ថាននៃការសិក្សាបណ្តើរ។

ក្តារផ្គុំអក្សារក-ខជួយកុមារក្នុងការបង្ហាញអំពីចំណូលចិត្តលើតួអក្សរ ដោយឱ្យកុមារចេះផ្ទៀងផ្ទាត់រូបរាងអក្សរបណ្តើរទំលាប់នឹងតួអក្សរទាំង៣៣តួបណ្តើរ ព្រមទាំងជួយឱ្យកុមារស្គាល់តួអក្សរទាំងអស់លើតារាងព្យញ្ជនៈ។ តាមបទពិសោធន៍ នៅក្នុងខេត្តកណ្តាល ទោះជាមិនមានរូបភាព ក៏កុមារអាចរៀបផ្គុំអក្សរយ៉ាងយកចិត្តទុកដាក់ដែរ។ ដូច្នេះហើយបានជាអង្គការ យើងយល់ឃើញថាសម្ភារឧបទ្ទេស-ល្បែងសិក្សានេះមានភាពងាយស្រួលជាងការមើលឃើញ។

**[អាយុគោលដៅ]**

១. សម្រាប់កុមារចាប់ពីអាយុ៤ឆ្នាំឡើងទៅ។

**[គោលបំណង]**

១. ឱ្យកុមារដឹងអំពីភាពខុសគ្នានៃរូបរាងរបស់ព្យញ្ជនៈទាំង៣៣តួ។
២. ឱ្យកុមារដឹងអំពីភាពខុសគ្នានៃសូរសំលេងរបស់ព្យញ្ជនៈទាំង៣៣តួ។
៣. ឱ្យកុមារផ្ទៀងផ្ទាត់តារាងព្យញ្ជនៈបណ្តើរ ចេះរៀបអក្សរបណ្តើរតាមលំដាប់ព្យញ្ជនៈ។
៤. បង្កើនកំលាំងចក្ខុវិញ្ញាណ ដើម្បីរៀបអក្សរ។
៥. បង្កើនកំលាំងផ្ចង់អារម្មណ៍ ដើម្បីរៀបអក្សរ។

**[របៀបបង្ហាញទៅកុមារ]**

១. បង្ហាញកុមារឱ្យដឹងថាតារាងព្យញ្ជនៈដែលបិទនៅក្នុងថ្នាក់ និងតារាងព្យញ្ជនៈសំរាប់ផ្ទៀងផ្ទាត់(តារាងពិណ)នេះ គឺដូចគ្នា។
២. ប្រើប្រាស់ក្តារដែលមានបិទតួអក្សរដូចអក្សរក្នុងតារាងព្យញ្ជនៈសំរាប់ផ្ទៀងផ្ទាត់(ក្តារបិទអក្សរមានពណ៌)
   ២.១. ញែកកូនកាតដែលមានពណ៌ខុសគ្នាចេញ(ពិណផ្កាឈូកដាក់ម្ដុំ ពណ៌ខៀវដាក់ម្ដុំដោយតំរៀបតួអក្សរឱ្យត្រូវទិសគ្នា) ដើម្បីងាយរកអក្សរ ឧទាហរណ៍ ពេលរៀបដល់អក្សរពណ៌ខៀវ កុមារងាករកក្នុងក្រុមខៀវ។

២.២. ឱ្យកុមាររកតួអក្សរដែលមានរូបរាងដូចគ្នាជាមួយតួអក្សរដែលបិទក្នុងក្ដារផ្គុំ ពេលរកឃើញហើយយកកូនកាតនោះមកផ្ទៀងផ្ទាត់ជាមួយតួអក្សរក្នុងស៊ុំ រួចដាក់លើអក្សរនោះ ។

២.៣. គ្រូអានតួអក្សរនោះឱ្យកុមារស្ដាប់ រួចឱ្យកុមារអានតាម ។

២.៤. ធ្វើតាមលេខរៀង ២.២ និង២.៣

២.៥. នៅពេលផ្គុំចប់ សូមគ្រូអានតួអក្សរនីមួយៗដោយឱ្យកុមារអានតាមម្ដង១អក្សរៗ តាមលំដាប់លំដោយ ពីដំបូងរហូតដល់ចប់ ។

៣. ប្រើប្រាស់ក្ដារដែលមានបិទតួអក្សរថតចំលងស-ខ្មៅ

៣.១. អនុវត្តតាមលំដាប់ដូចគ្នាពី២.១ រហូតដល់២.៥

៤. ប្រើប្រាស់ក្ដារទទេជាមួយតារាងព្យញ្ជនៈសម្រាប់ផ្ទៀងផ្ទាត់( តារាងពណ៌)

៤.១. រៀបអក្សរម្ដងមួយៗតាមលំដាប់តួអក្សរលើក្ដារទទេ ដោយមើលតារាងពណ៌ រៀបមួយជួរម្ដង រួចទាញក្ដារចុះក្រោម រៀបមួយជួរទៀត ។

៥. ប្រើប្រាស់ក្ដារទទេ ដោយឱ្យកុមារផ្គុំអក្សរពី "ក" រហូតដល់ "អ" មួយចប់ដោយខ្លួនឯងដោយមិនមើលអ្វីទាំងអស់ ពេលផ្គុំចប់ ទើបយកតារាងពណ៌នោះមកផ្ទៀងផ្ទាត់( មិនបាច់តាមលំដាប់លំដោយអក្សរទេ) ។

[ចំណុចត្រូវប្រុងប្រយ័ត្ន]

១. កុំប្រញាប់ប្រញាល់ឱ្យកុមារអានអក្សរលឿនពេក ។ ប្រការសំខាន់គឺឱ្យកុមារមានចំណូលចិត្ត និងចង់សាកល្បងផ្ទៀងផ្ទាត់រូបរាងអក្សរដោយខ្លួនឯង ។

២. ជាការចាំបាច់ណាស់ដែលត្រូវធ្វើយ៉ាងណាឱ្យកុមារសប្បាយរីករាយ ហើយមានអារម្មណ៍ថាខ្លួនឯងអាចធ្វើបានដោយជោគជ័យ ។

៣. នៅពេលកុមាររកឃើញតួអក្សរដែលមានរូបរាងដូចគ្នាហើយ សូមអានតួអក្សរនោះឱ្យបានត្រឹមត្រូវពេលដាក់ចូលក្នុងស៊ុំក្ដារនីមួយៗ ។

៤. សូមប្រយ័ត្នកុំឱ្យបាត់កូនកាតទាំង៣៣តួ ។ ករណីបាត់សូមធ្វើកូនកាតនោះដោយដៃមកជំនួសវិញភ្លាម ។

[ចំណុចល្អរបស់ក្ដារផ្គុំអក្សរ]

១. ដោយមានស៊ុំជុំវិញអក្សរនីមួយៗ ពេលតំរៀបកូនកាតរួចទាំង៣៣តួ កូនកាតទាំងនោះមិនធ្លាក់ច្របល់ចូលគ្នាវិញទេ ដូច្នេះអាចធ្វើឱ្យកុមារមានចិត្តចង់បន្តទៀតដោយមិនធុញទ្រាន់ ។

២. ចាប់ផ្ដើមផ្គុំពីរបៀបងាយៗទៅ ដូច្នេះអាចបង្កើតចំណាប់អារម្មណ៍របស់កុមារបាន ទោះជាកុមារដែលមិនពូកែក៏មានចិត្តចង់សាកល្បងផ្គុំដែរ ។

៣. កូនកាតទាំង៣៣តួអក្សរមានពីរពណ៌ដូច្នេះកុមារងាយរកឃើញ និងចេះបែងចែកសូរសំលេងអឃោសៈ "អ" និងសំលេងឃោសៈ "អ៊" បានទៀតផង ។

៤. មានកំប៉ុងជ័រសំរាប់ដាក់កូនកាត ដូច្នេះងាយស្រួលក្នុងការរៀបចំទុកដាក់និងថែរក្សា ។

៥. ដោយសារមានតារាងព្យញ្ជនៈសម្រាប់ផ្ទៀងផ្ទាត់( តារាងពណ៌) ដូច្នេះកុមារអាចផ្ទៀងផ្ទាត់ដោយខ្លួនឯងបាន ហើយដោយសារការផ្គុំបានចប់ជាស្ថាពរ ធ្វើឱ្យកុមារមានអារម្មណ៍ថាខ្លួនឯងអាចធ្វើបានជោគជ័យ ។